**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះដែលចូលជាធរមានចាប់តាំងពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ : ៦៥ អនក្រ

## ស្តីពីការរៀបចំឃុំ ស្រុក ភូមិខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ជាពិសេសមាត្រា ១២៦

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើតឃុំថ្មីចំនួនបី ក្នុងស្រុកថ្មពួកគឺ :

១_ឃុំគោកកបិន មានចំនួនប្រាំបួនភូមិ ដែលកាត់យកប្រាំពីរភូមិ របស់ឃុំថ្មពួក គឺ ÷ ភូមិជី ភូមិស្ពៅ ភូមិទ្រាស ភូមិគោកកបិន ភូមិតាសៀវ ភូមិជន្លះដៃ ភូមិតាត្រៃ និងកាត់យកពីរភូមិរបស់ឃុំភូមិថ្មី គឺភូមិព្រះឈរ និងភូមិគោកខ្ពស់ ។

២_ឃុំគំរូមានបួនភូមិ ដែលកាត់យកបីភូមិរបស់ឃុំថ្មពួក គឺ ភូមិតាយឹង ភូមិអណ្តូងខ្លុង ភូមិគំរូ និងកាត់យកភូមិកណ្តាល របស់ឃុំគោករមៀត ។

៣-ឃុំរលួសមានប្រាំមួយភូមិដែលកាត់យកពីឃុំស្វាយចេកគឺ : ភូមិស្ទឹង ភូមិខ្វាវកើត ភូមិស្លែង ភូមិបែកចានថ្មីភូមិតាអុងកើត ភូមិរលួស ។

**មាត្រា ២ :** ត្រូវបានបំបែកភូមិសាស្ត្រស្រុកថ្មពួក ជាពីរស្រុកគឺ : ស្រុកស្វាយចេក និងស្រុកថ្មពួក ។

-ស្រុកស្វាយចេកមានឃុំចំណុះចំនួនប្រាំបី គឺ ឃុំស្វាយចេក ឃុំរលួស ឃុំតាបែន ឃុំស្លក្រាម ឃុំសារង្គ ឃុំតាផូ ឃុំផ្គាំ ឃុំទ្រាស ។ ទីតាំងរដ្ឋាបាលរបស់សាលាស្រុកស្វាយចេក តាំងនៅភូមិស្ទឹង ឃុំស្វាយចេក ។

-ស្រុកថ្មពួកមានឃុំចំណុះចំនួនប្រាំមួយគឺ : ឃុំថ្មពួក ឃុំគោកកបិន ឃុំគុំរូ ឃុំបន្ទាយឆ្មារ ឃុំភូមិថ្មី ឃុំគោករមៀត ។ ទីតាំងរដ្ឋបាលរបស់ស្រុកថ្មពួកតាំងនៅ ភូមិវត្តចាស់ ឃុំថ្មពួក ។

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តបន្ទាយមានជ័យ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះមាន អានុភាពតតិយុត្តិចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៦៦ អនក្រ
## ស្តីពីការកែសំរួលសមាសភាពគណៈកម្មការ
## ជាតិអចិន្ត្រៃយ៍ដើម្បី សំរបសំរួលកិច្ចការឯកជន
## ភាវូបនីយកម្ម និង ការជំរុញវិស័យដំណាំកៅស៊ូ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា